សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

# របាយការណ៍សង្ខេប ការនាំចេញអង្ករកម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០២១

# SUMMARY REPORT OF RICE EXPORT JULY 2021



## ការនាំចេញអង្ករក្នុងខែទីមួយ នៃឆមាសទី២ ឆ្នាំ២០២១ ចាប់ផ្តើមងើបឡើងបន្តិច

ក្នុងខែកក្កដា ឆ្នាំ២០២១ នេះ ការនាំចេញអង្កររបស់កម្ពុជា បានចំនួន ២៩,៤១៥ តោនគិតជាទឹកប្រាក់ចំនួន ២១.១៨លានដុល្លារ មានការកើនឡើងចំនួន ៣.៥៣% បើធៀបទៅនឹងបរិមាណនាំចេញក្នុងខែកក្កដា ឆ្នាំ ២០២០ ឬ កើន ១១.១០% បើធៀបទៅបរិមាណនាំចេញក្នុងខែកក្កដា ឆ្នាំ២០១៩។

ទោះបីជា ស្ថានភាពនៃកង្វះទូកុងតែន័រនៅតែបន្ត តម្លៃកប៉ាល់ទៅកាន់ទីផ្សារនៅក្នុងសហគមន៍អ៊ឺរ៉ុបនៅតែបន្តឡើងថ្លៃ តែស្ថានភាពទីផ្សារតម្រូវបានជំរុញឱ្យការនាំចេញអង្ករកម្ពុជា ចាប់ផ្តើមដំណើរការ ជាពិសេសការបំពេញការនាំចេញលើកិច្ចសន្យាដែលខកខាន ឬ ពន្យារពេលកន្លងមក។

សម្រាប់ខែកក្កដានេះ ការនាំចេញអង្ករក្រអូបប្រណិតបានចំនួន៤៥%, អង្ករក្រអូបធម្មតា (សែនក្រអូប) ៣៥%, អង្ករស បាយទន់ ១៧% ហើយអង្ករចំហុយបានចំនួន ៣% ដែលអង្ករនាំចេញ ទាំងនោះចំនួន ៣៦.២១% ទៅកាន់សហគមន៍អ៊ឺរ៉ុប ៣៦.១៣% នាំទៅកាន់ប្រទេសចិន ៧.៨៨% ទៅកាន់ទីផ្សារសហគមន៍អាស៊ាន និង ១៩.៧៩% ទៅកាន់ទីផ្សារផ្សេងៗចំនួន ២២ គោលដៅ ដូចជា ហ្គាប៊ុង អូស្ត្រាលី អង់គ្លេស ញ៉ូហ្សេលេន..ជាដើម។

ការនាំចេញអង្ករទៅកាន់ទីផ្សារគោលដៅ ខែកក្កដា ឆ្នាំ២០២១

Rice Export by Destinations July 2021




ការនាំចេញអង្ករតាមប្រភេទ ខែកក្កដា ឆ្នាំ២០២១

Rice Export by Varieties in July 2021




សម្រាប់ការនាំចេញស្រូវ ជាពិសេសស្រូវប្រាំងដែលបាន និងកំពុងប្រមូលផល ក្នុងខែកក្កដា នេះបានចំនួន ៣២៥ ៤២៨ តោន គិតជាទឹកប្រាក់ចំនួនប្រមាណជាង៧៨លានដុល្លារសហរដ្ឋអាមេរិក។ ការនាំចេញស្រូវក្នុងខែកក្កដា ឆ្នាំ ២០២១ នេះមានការកើនឡើងគួរឱ្យកត់សំគាល់ ទោះបីជាមានការរាំងស្ទះខ្លះ ដោយសារវិធានការសុវត្ថិភាពប្រឆាំងកូវីដ១៩ នៅតាមព្រំដែនជាមួយប្រទេសវៀតណាម ត្រូវបានរឹតបន្តឹងក៏ដោយ។

ប្រទេសកម្ពុជាបាននិងកំពុងប្រមូលផលស្រូវប្រាំងជុំទី២ ចន្លោះពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២១ លើផ្ទៃដី ៥៦៣ ៣៩៤ហិកតា ហើយរំពឹងនឹងទទួលបានទិន្នផល ប្រមាណ ២.៨២លានតោន។

ជារួមការនាំចេញអង្ករសរុប ក្នុងរយៈពេល៧ខែ ឆ្នាំ ២០២១ បានចំនួន ៣០៩៨៦៥ តោន គិតជាទឹកប្រាក់ចំនួន ២២៣.៨៥លាន ដុល្លាសហរដ្ឋអាមេរិក ហើយការនាំចេញស្រូវបានចំនួន ២ ០០៨ ២៤១ តោន គិតជាទឹកប្រាក់ចំនួន ជាង ៥០៣.០៩លានដុល្លារសហរដ្ឋអាមេរិក។ ចំណូលដុលសម្រាប់វិស័យស្រូវអង្ករកម្ពុជាបានពីការនាំចេញ មានចំនួន ៧២៦.៩៤លានដុល្លារសហរដ្ឋអាមេរិក។

## បរិមាណអង្ករនាំចេញ ក្នុងខែកក្កដា ពីឆ្នាំ២០១៧ ដល់ ២០២១
## RICE EXPORT IN JULY FROM 2017-2021





# Cambodia’s Rice Export in the First month of Second Semester 2021 is slightly increased

In July 2021, Cambodia exported 29,415 tons of milled-rice worth USD 21.18 million, an increase of 3.53% compared to the volume exported in July 2020 or increase of 11.10% compared to export volume in July 2019.

Although the issue of container shortage and the high cost of sea freight to EU markets, the market’s conditions have resumed to be back as normal and Cambodia’s rice exports to resume positively, especially for exporters who missed or delayed delivery from first semester.

For this July 2021, exports of premium fragrant rice accounted for 45%, fragrant rice (SKO) 35%, white rice (soft cooking) accounted for 17%, and parboiled rice 3%.

The export of 36.21% to the Europe Union (EU), 36.13% to Chi and its’ autonomous region, 7.88% to ASEAN market, and 19.79% to 22 other market destinations such as Gabon, Australia, UK, New Zealand. Etc.

ការនាំចេញអង្ករទៅកាន់ទីផ្សារគោលដៅ ខែកក្កដា ឆ្នាំ២០២១
Rice Export by Destinations July 2021






By the way, the export of paddy, especially short-term crop or dry season has been exported 325 428 tons, worth about USD 78 million. The paddy exports in July 2021 increased significantly, despite some challenges such as the measurement tightened to prevent the COVID-19 at along the borders with Vietnamese.




Cambodia is going to harvest the second round of dry season rice/ dry season in 2021 from July to September 2021 on the area of 563,394 hectares, and the production outputs are about 2.82 million tons.

In overall, the exports of milled rice for 7 months of 2021 are 309 865 tons equivalence to 223.85 million USD and it has exported paddy rice about 2,008,241 ton generates 503.09 million USD. Total exports of milled rice and paddy for seven months of year 2021 are 726.94 million USD.

ប្រភព៖
ទិន្នន័យនៃការនាំចេញសម្រាប់ ខែមករា ដល់ ខែកក្កដា ឆ្នាំ ២០២១
១. អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២. អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៣. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម

Source:
Data of Cambodia's rice export from Jan-June 2021
1. General Directorate of Agriculture (GDA) of Ministry of Agriculture, Forestry, and Fisheries (MAFF)
2. General Department of Customs and Excise of Cambodia of Ministry of Economic and Finance (MEF)
3. General Department of Trade Support Services, Ministry of Commerce (MoC)

## រៀបរៀងដោយ (PREPARED BY)


លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា (SECRETARIAT OF CAMBODIA RICE FEDERATION)


## CONTACT US


www.crf.org.kh

សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation - CRF

Cambodia Rice Federation
@RiceCrf

ព័ត៌មានស្រូវអង្ករកម្ពុជា
Cambodia Rice News

សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

Olympia City, Fortune Tower C7, 8th floor, room 819
Address: Street 182, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia
Cambodia Mail Box of CRF office at Fortune Tower C7 : SOHO 819 (Cambodia Rice Federation)